សេចក្តីថ្លែងការណ៍

កិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៥-១៦ ខែវិច្ឆិកា ឆ្នាំ ២០២៦

"រួមគ្នាបន្តកសាងសន្តិភាព ដើម្បីវិបុលភាពរួម និងស្ថិរភាពយូរអង្វែង"

បុព្វកថា

យើងជាប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលនៃបណ្តាប្រទេសប្រើប្រាស់ភាសាបារាំង បានជួបប្រជុំគ្នានៅថ្ងៃទី ១៥ និងទី១៦ ខែវិច្ឆិកា ឆ្នាំ ២០២៦ នៅភ្នំពេញ រាជធានីនៃព្រះរាជាណាចក្រកម្ពុជា មាតុភូមិរបស់ព្រះករុណា ព្រះបរមរតនកោដ្ឋ ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះបិតាស្ថាបនិកមួយអង្គ ក្នុងចំណោមបិតាស្ថាបនិកផ្សេងទៀតនៃអង្គការអន្តរជាតិកាលហ្វ្រង់កូហ្វូនី ក្នុងឱកាសកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០;

យើងរីករាយ នឹងនិមិត្តរូបនៃការវិលត្រឡប់មកកាន់ទឹកដីអាស៊ីជាថ្មីម្តងទៀតនៃកិច្ចប្រជុំកំពូលអង្គការហ្វ្រង់កូហ្វូនី ក្រោយពីជិត៣០ឆ្នាំមុន កិច្ចប្រជុំកំពូលលើកទី៧ បានប្រព្រឹត្តទៅនៅទីក្រុងហាណូយ (វៀតណាម) អគ្គលេខាធិការហ្វ្រង់កូហ្វូនីដំបូងគេបង្អស់ គឺឯកឧត្តមប៊ូត្រូស ប៊ូត្រូស ហ្គាលី (Boutros BOUTROS-GHALI);

ដោយបញ្ជាក់ជាថ្មីអំពីការគោរពគុណតម្លៃគ្រឹះរបស់ហ្វ្រង់កូហ្វូនី ដូចមានក្នុងធម្មនុញ្ញហ្វ្រង់កូហ្វូនីនិងឯកសារពាក់ព័ន្ធ ជាពិសេសសេចក្តីប្រកាសទីក្រុងបាម៉ាកូ (Bamako) ឆ្នាំ២០០០ និងទីក្រុងសាំងបូនីហ្វាស (Saint-Boniface) ឆ្នាំ២០០៦ ដែលចែងអំពីសន្តិភាព លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស ក៏ដូចជាភាពចម្រុះនៃវប្បធម៌និងភាសា និងការអភិវឌ្ឍប្រកបដោយចីរភាព អនុលោមតាមធម្មនុញ្ញអង្គការសហប្រជាជាតិនិងច្បាប់អន្តរជាតិ ;

ដោយបញ្ជាក់ជាថ្មី អំពីការប្តេជ្ញាចិត្តរបស់យើងក្នុងការលើកស្ទួយភាសាបារាំង ដែលជាភាសាសម្រាប់កិច្ចសន្ទនា និងកិច្ចចរចានៅលើវេទិកាអន្តរជាតិ ជាភាសាច្បាប់ ជាភាសាសម្រាប់អប់រំ និងបណ្តុះបណ្តាលដែលជាកម្លាំងចលករដ៏រឹងមាំសម្រាប់ការបង្កើត ការច្នៃប្រឌិត សាមគ្គីភាព និងវិបុលភាព ជាភាសានៃការដោះដូរទៅវិញទៅមកផ្នែកវប្បធម៌ វិទ្យាសាស្ត្រ និងសេដ្ឋកិច្ច ស្របតាមស្មារតីនៃសេចក្តីប្រកាសស្តីពីភាសាបារាំងក្នុងភាពចម្រុះនៃភាសារបស់អង្គការហ្វ្រង់កូហ្វូនី (2022);

ដោយទទួលស្គាល់ អំពីបញ្ហាប្រឈមជាច្រើនដែលប្រជាជនរបស់យើងកំពុងជួបប្រទះ នៅក្នុងបរិបទនៃសណ្តាប់ធ្នាប់អន្តរជាតិមួយដែលមានភាពកាន់តែមិនច្បាស់លាស់និងបែកបាក់ មិនធ្លាប់មានពីមុនមក; ក្នុងន័យនេះ យើងសូមគូសបញ្ជាក់ឡើងវិញនូវការប្រកាន់ខ្ជាប់ឥតងាករេរបស់យើងចំពោះពហុភាគី

និយម និងការគោរពច្បាប់អន្តរជាតិ ព្រមទាំងការយល់ច្បាស់អំពីតម្រូវការពង្រឹងសកម្មភាពរបស់ហ្វ្រង់កូហ្វូនី ដើម្បីផ្តល់ជំណោះស្រាយជាក់ស្តែងចំពោះបញ្ហាប្រឈមទាំងនេះ;

យើងជឿជាក់ថា សន្តិភាព វិបុលភាព និងស្ថិរភាព នៅគ្រប់ពេលវេលានិងគ្រប់ទីកន្លែង គឺមិនអាចកាត់ផ្តាច់ពីគ្នាបានទេ ហើយកិច្ចសន្ទនាគឺជាមធ្យោបាយដ៏ចាំបាច់បំផុត ដើម្បីសម្រេចគោលបំណងទាំងនេះ;

ដោយអះអាងជាថ្មី ក្នុងន័យនេះថា អង្គការហ្វ្រង់កូហ្វូនីដែលជាអង្គការមានភាពរឹងមាំដោយសារគុណតម្លៃ និងលក្ខណៈពិសេសផ្ទាល់ខ្លួន មានភាតព្វកិច្ចចូលរួមចំណែកតាមរយៈការប្តេជ្ញាចិត្តខ្ពស់និងការដើរតួនាទីបំពេញបន្ថែមគ្នាពីសំណាក់គ្រប់តួអង្គទាំងអស់នៃធម្មនុញ្ញអង្គការនេះ ;

ដោយមានជំនឿថា ថាមពលប្រកបដោយភាពច្នៃប្រឌិតរបស់យុវជន និងកម្លាំងរុញច្រានរបស់ស្ត្រីទៅរកការផ្លាស់ប្តូរ បាននិងកំពុងបន្តជួយពង្រឹងការកសាងលំហហ្វ្រង់កូហ្វូនីមួយប្រកបដោយសន្តិភាពនិងវិបុលភាព ដើម្បីជាប្រយោជន៍ដល់មនុស្សជំនាន់បច្ចុប្បន្ននិងអនាគត ;

ដោយទទួលស្គាល់ អំពីតួនាទីសំខាន់របស់យុវជននិងស្ត្រី ក្នុងការកសាង ថែរក្សា និងពង្រឹងសន្តិភាពតាមរយៈការចូលរួមយ៉ាងសកម្មប្រកបដោយបរិយាបន្ននិងពោរពេញទៅដោយអត្ថន័យ ដែលទាំងអស់នេះជាការចាំបាច់បំផុតសម្រាប់ភាពធន់នៃសង្គម យើងសូមបញ្ជាក់ឡើងវិញអំពីការប្តេជ្ញាចិត្តពង្រឹងតួនាទីទាំងនេះ ដូចដែលមានចែងនៅក្នុងសេចក្តីអំពាវនាវទីក្រុងគីហ្គាលី ដែលត្រូវបានអនុម័តក្នុងសម័យប្រជុំលើកទី៤៦នៃសន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនី(CMF) នៅទីក្រុងគីហ្គាលី (Rwanda) ;

ដោយទទួលស្គាល់ថា ត្រូវតែធ្វើសកម្មភាពរួមគ្នាបន្ទាន់ ជាមួយនឹងការតាំងចិត្ត ព្រមទាំងការប្រកាន់ខ្ជាប់នូវគោលការណ៍នៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋាភិបាលជាសមាជិក ឈរលើមូលដ្ឋាននៃទំនុកចិត្តសាមគ្គីភាព និងការទទួលខុសត្រូវ;

ដោយបញ្ជាក់ឡើងវិញ ជាឱឡារិកថា សន្តិភាព និងស្ថិរភាព មិនអាចឋិតឋេរជានិរន្តរ៍និងជាស្ថាពរនោះទេ ប្រសិនបើគ្មានការថែរក្សាការពារ;

អាស្រ័យហេតុនេះ យើងសម្រេចចិត្តជ្រើសរើស «រួមគ្នាបន្តកសាងសន្តិភាព ដើម្បីវិបុលភាពរួម និងស្ថិរភាពយូរអង្វែង» ជាមូលបទសម្រាប់កិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០៖

1). **យើងសូមបញ្ជាក់ឡើងវិញ** ពីការប្តេជ្ញាចិត្ត ក្នុងការប្រមូលគ្រប់ស្ថាប័នហ្វ្រង់កូហ្វូនីទាំងអស់ឱ្យចូលរួមក្នុងសកម្មភាពនានា ដើម្បីសន្តិភាពនិងស្ថិរភាព;

2). ក្នុងន័យនេះ **យើងគាំទ្រ**គ្រប់សកម្មភាពរបស់អង្គការអន្តរជាតិហ្វ្រង់កូហ្វូនីក្នុងការលើកកម្ពស់នីតិរដ្ឋ និងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ដែលនឹងជួយពង្រឹងប្រសិទ្ធភាពស្ថាប័ន និងប្រសិទ្ធិភាពនៃការបោះឆ្នោតប្រកបដោយទំនុកចិត្ត បរិយាបន្ននិងនិរន្តរភាព;

3). **យើងលើកទឹកចិត្ត**ឱ្យមានការពង្រឹងសកម្មភាពរបស់អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ដើម្បីចូលរួមទប់ស្កាត់និងគ្រប់គ្រងវិបត្តិ ព្រមទាំងគាំទ្រដំណើរការសន្តិភាព ជាពិសេសតាមរយៈគំនិតផ្តួចផ្តើមក្នុងការដើរតួនាទីជាអន្តរការី ក៏ដូចជាការចូលរួមគាំទ្រអន្តរកាលប្រជាធិបតេយ្យ;

4). **យើងអំពាវនាវ**ឱ្យមានការពង្រឹងយន្តការនៃកិច្ចសន្ទនារវាងអង្គការតំបន់និងអន្តរជាតិ; និងស្វាគមន៍ចំពោះគំនិតផ្តួចផ្តើមរបស់អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ក្នុងការចូលរួមសម្របសម្រួលឱ្យកិច្ចសន្ទនាទាំងនេះនាំមកនូវលទ្ធផល;

5). **យើងគាំទ្រ**ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី និងអង្គការអន្តរជាតិព្រមទាំងអង្គការតំបន់ផ្សេងៗទៀត ជាពិសេសសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) និងសហគមន៍ប៉ាស៊ីហ្វិក(CPS);

6). **យើងបញ្ជាក់ជាថ្មី**ថា សកម្មភាពនានាដើម្បីយុវជន គឺជាអាទិភាពយុទ្ធសាស្ត្ររបស់ហ្វ្រង់កូហ្វូនី; **យើងលើកទឹកចិត្ត**ឱ្យមានការចូលរួមពីសំណាក់យុវជនក្នុងនាមជាពលរដ្ឋល្អ ក្នុងនាមជាកម្លាំងជម្រុញសាមគ្គីភាពនិងការផ្លាស់ប្តូរសង្គម ដើម្បីជាប្រយោជន៍ដល់សន្តិភាព សិទ្ធិមនុស្ស និងការអភិវឌ្ឍដោយ ចីរភាព។ ក្នុងន័យនេះ **យើងប្តេជ្ញា**ជំរុញសកម្មភាពជាក់ស្តែង តាមរយៈបណ្តាញយុវជនហ្វ្រង់កូហ្វូនី ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុក និងបំណងប្រាថ្នាសមស្របរបស់យុវជនដើម្បីអនាគតរួម ;

7). **យើងតម្រូវ**ឱ្យគ្រប់តួអង្គហ្វ្រង់កូហ្វូនីទាំងអស់ ឱ្យពង្រឹងនិងពង្រីកសកម្មភាពអប់រំដើម្បីសន្តិភាពដែលសកម្មភាពទាំងនេះចូលរួមចំណែកដល់ការបង្ការនិងការដោះស្រាយជម្លោះផង ព្រមទាំងការកាត់បន្ថយអំពើហិង្សាផង ស្របតាមស្មារតីនៃសេចក្តីសម្រេចចិត្តលេខ A/RES/80/266 របស់មហាសន្និបាតអង្គការសហប្រជាជាតិ;

8). **យើងនៅតែបន្តបារម្ភ**ចំពោះនិន្នាការបាត់បង់ជំនឿលើស្ថាប័នផ្លូវការនានា និងផលវិបាករបស់វាទៅលើដំណើរការប្រជាធិបតេយ្យ; **យើងគូសបញ្ជាក់**អំពីសារៈសំខាន់នៃការលើកកម្ពស់សកម្មភាពអប់រំឱ្យទៅជាពលរដ្ឋល្អ; **យើងលើកទឹកចិត្ត**ហ្វ្រង់កូហ្វូនីឱ្យបន្តខំប្រឹងប្រែងលើកកម្ពស់នីតិរដ្ឋ អភិបាលកិច្ចបែបប្រជាធិបតេយ្យ ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ កិច្ចសន្ទនាប្រកបដោយបរិយាបន្ន ការទទួលបានឱកាសដោយសមធម៌ និងភាពសុខដុមរមនាក្នុងសង្គមនៅក្នុងលំហហ្វ្រង់កូហ្វូនី;

9). **យើងជឿជាក់ថា** ការផ្លាស់ប្តូររវាងប្រជាជន គឺជាកត្តាសំខាន់សម្រាប់សាមគ្គីភាពនិងសន្តិភាព ; ក្នុងន័យនេះ **យើងវាយតម្លៃខ្ពស់**ចំពោះផលវិជ្ជមាននៃកម្មវិធីនានា ក្នុងការជំរុញសកម្មភាពយុវជនហ្វ្រង់កូហ្វូនី ជាពិសេសកម្មវិធីដែលត្រូវបានដាក់ឱ្យដំណើរការតាំងពីកិច្ចប្រជុំកំពូលវីឡេ-កូទើរ៉ Villers-Cotterêts (ឆ្នាំ២០២៤) មក ព្រមទាំងសូមអំពាវនាវឱ្យបន្តផ្តល់អាទិភាពដល់ការគាំទ្រគំនិតផ្តួចផ្តើមទាំងនេះ ;

10). **យើងបញ្ជាក់ជាថ្មី**នូវការប្តេជ្ញាចិត្តរបស់យើង ក្នុងការរក្សាឱ្យបាននូវលំហព័ត៌មានមួយដែលមានគុណភាពខ្ពស់គួរជាទីទុកចិត្តនិងត្រឹមត្រូវ ស្របតាមស្មារតីនៃ «សេចក្តីអំពាវនាវទីក្រុង Villers-Cotterêts» ដើម្បីឱ្យមានលំហឌីជីថលមួយប្រកបដោយភាពស្មោះត្រង់ និងគួរជាទីទុកចិត្ត នៅក្នុងលំហហ្វ្រង់កូហ្វូនី។ ក្នុងន័យនេះ **យើងស្វាគមន៍**ចំពោះការចូលរួមយ៉ាងសកម្មរបស់បណ្តាញនិយ័តករប្រព័ន្ធផ្សព្វផ្សាយហ្វ្រង់កូហ្វូនី(REFRAM) នៅក្នុងកិច្ចសន្ទនារវាងអាជ្ញាធរនិយ័តកម្មនិងឋាលឌីជីថលនានា ;

11). **យើងអំពាវនាវ** ឱ្យពង្រឹងការកៀរគរកម្លាំងនៅក្នុងលំហហ្វ្រង់កូហ្វូនីទាំងមូល ដើម្បីប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយព្រមទាំងការជ្រៀតជ្រែកពីបរទេស ដែលអាចបង្កអស្ថិរភាពដល់ស្ថាប័នប្រជាធិបតេយ្យ និងដើម្បីលើកកម្ពស់កម្មវិធីអប់រំផ្នែកប្រព័ន្ធផ្សព្វផ្សាយនិងព័ត៌មាន;

12). **យើងបញ្ជាក់សាជាថ្មី** អំពីភាពចាំបាច់ក្នុងការធានាឱ្យមានការគោរពពិតប្រាកដចំពោះសេរីភាពសារព័ត៌មាន និងការលើកកម្ពស់ពហុនិយមនៃប្រព័ន្ធផ្សព្វផ្សាយដែលមានវិជ្ជាជីវៈនិងការទទួលខុសត្រូវជាមួយនឹងការធានាបាននូវព័ត៌មានគួរឱ្យទុកចិត្តប្រកបដោយគុណភាព និងគ្មានភាសាញុះញង់ឱ្យមានការស្អប់ខ្ពើមរើសអើង ;

13). ក្នុងន័យនេះ **យើងបញ្ជាក់ជាថ្មី**អំពីសមានចិត្តរបស់យើងចំពោះទូរទស្សន៍ប៉ុស្តិ៍លេខ៥ (TV5) ដែលជាបណ្តាញផ្សព្វផ្សាយចម្រុះសាធារណៈ និងដែលរួមចំណែកដល់ការផ្សព្វផ្សាយសេដ្ឋកិច្ចនិងវប្បធម៌របស់ហ្វ្រង់កូហ្វូនី ព្រមទាំងដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនលទ្ធភាពឱ្យគេស្គាល់នូវមាតិកាសោតទស្សន៍របស់សហគមន៍ហ្វ្រង់កូហ្វូនី និងជំរុញការសិក្សាភាសាបារាំង ; **យើងបញ្ជាក់ជាថ្មី** នូវការប្តេជ្ញាចិត្តរបស់យើង ក្នុងការចាត់វិធានការសមស្រប ដើម្បីធានាថាការចាក់ផ្សាយនានារបស់ TV5MONDE ទាំងសម្រាប់កម្មវិធីទូទៅ ទាំងសម្រាប់កម្មវិធីកុមារ (TiVi5MONDE) និងទាំងលើថ្នាលឌីជីថល (TV5MONDE+) ទទួលបានលក្ខខណ្ឌអំណោយផល ដូចគ្នាទៅនឹងបណ្តាញទូរទស្សន៍ជាតិ ហើយយើង**បញ្ជាក់ជាថ្មី**នូវការប្តេជ្ញាចិត្តរបស់យើងក្នុងការគាំទ្រ និងលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយទាំងនេះ;

14). **យើងទទួលស្គាល់**សក្តានុពលនៃបរិវត្តកម្មបញ្ញាសិប្បនិម្មិត (IA) ដែលជានវានុវត្តន៍ផ្នែកបច្ចេកវិទ្យាឈានមុខ ថាជាកម្លាំងជំរុញផលិតភាព ជំរុញការប្រកួតប្រជែង និងជំរុញការធ្វើទំនើបកម្ម ដែលនឹងជួយលើកកម្ពស់វិបុលភាពរួម ;

15). **យើងប្រកាន់ជំហរ**ជាច់ខាតថា មនុស្សត្រូវតែជាចំណុចស្នូលនៃការផ្លាស់ប្តូរនេះ ដើម្បីធានាថាការអភិវឌ្ឍនិងការប្រើប្រាស់បញ្ញាសិប្បនិម្មិត គឺប្រកបដោយការទទួលខុសត្រូវ សីលធម៌ និងបរិយាបន្នដោយសារតែបញ្ញាសិប្បនិម្មិត បង្កប់នូវហានិភ័យនៃភាពលំអៀងមិនត្រឹមត្រូវ និងព័ត៌មានក្លែងក្លាយ ដែលអាចបង្កផលប៉ះពាល់ដល់ប្រជាជនដែលងាយរងគ្រោះ និងតុល្យភាពសង្គមយើង;

16). **យើងទទួលស្គាល់**ថា បញ្ញាសិប្បនិម្មិត មានឥទ្ធិពលខ្លាំងណាស់លើការបង្កើតថ្មី ការផ្សព្វផ្សាយ និងការទទួលបាននូវមាតិកាវប្បធម៌; យើងផ្តល់តម្លៃទៅលើសារៈសំខាន់នៃការអភិវឌ្ឍប្រកបដោយការទទួលខុសត្រូវ ដែលការពារនិងលើកកម្ពស់ភាពចម្រុះនៃការបង្ហាញវប្បធម៌ ដោយធានាឱ្យបាននូវការផ្តល់ប្រាក់កម្រៃសមរម្យដល់អ្នកបង្កើត ស្របតាមច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា និងសិទ្ធិពាក់ព័ន្ធ ;

17). **យើងផ្តោតការយកចិត្តទុកដាក់**លើទំហំយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការផលិត ការគ្រប់គ្រង និងការកែលំអជាប្រចាំ គុណភាពនៃទិន្នន័យដែលចេញពីលំហហ្វ្រង់កូហ្វូនី ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍបញ្ញាសិប្បនិម្មិតមួយ ដែលគោរពនិងឆ្លុះបញ្ចាំងនូវភាពចម្រុះនេះ;

18). **យើងអំពាវនាវ**ដល់ហ្វ្រង់កូហ្វូនី ឱ្យពង្រឹងការរួមចំណែករបស់ខ្លួនក្នុងកិច្ចការអភិបាលកិច្ចឌីជីថលសកលនិងក្នុងការអភិវឌ្ឍបញ្ញាសិប្បនិម្មិតមួយ ប្រកបដោយក្រមសីលធម៌និងទំនួលខុសត្រូវ ដែល

ផ្អែកលើគោលការណ៍រួមនៃបរិយាបន្ន និងសមធម៌ ស្របតាមកតិកាសញ្ញាឌីជីថលពិភពលោកអនុម័តនៅឆ្នាំ ២០២៤ និងលិខិតូបករណ៍អន្តរជាតិពាក់ព័ន្ធផ្សេងទៀត ក្នុងគោលដៅបង្កើតឱ្យមានភាពអន្តរប្រតិបត្តិការមួយប្រកបដោយស័ក្តិសិទ្ធភាព ;

19). ក្នុងន័យនេះ **យើងលើកទឹកចិត្ត**ហ្វ្រង់កូហ្វូនីឱ្យបន្តនិងពង្រឹងការចូលរួមរបស់ខ្លួនក្នុងវេទិកានៃកិច្ចចរចានិងនៃសេចក្តីសម្រេចចិត្តនានា ដែលទាក់ទិននឹងគោលនយោបាយឌីជីថល ជាអាទិ៍ក្នុងក្របខ័ណ្ឌនៃដំណើរការកិច្ចប្រជុំកំពូលពិភពលោកស្តីពីសង្គមព័ត៌មាន ក៏ដូចជាក្នុងក្របខ័ណ្ឌនាពេលខាងមុខនៃកិច្ចប្រជុំកំពូលស្តីពីបញ្ញាសិប្បនិម្មិតនាឆ្នាំ ២០២៧ នៅទីក្រុងហ្ស៊ីណែវ ;

20). **យើងលើកទឹកចិត្ត**ហ្វ្រង់កូហ្វូនី ឱ្យពង្រឹងសមត្ថភាពនិងជំនាញផ្នែកបច្ចេកវិទ្យាឌីជីថល និងបញ្ញាសិប្បនិម្មិត ជាពិសេសក្នុងចំណោមយុវជននិងស្ត្រី ដើម្បីជំរុញឱ្យពួកគេទទួលបាននូវជំនាញត្រឹមត្រូវនិងអាចចូលប្រឡូកក្នុងសង្គមសេដ្ឋកិច្ចបាន;

21). **យើងបញ្ជាក់ជាថ្មី**នូវសក្តានុពលនៃហ្វ្រង់កូហ្វូនីសេដ្ឋកិច្ច (Francophonie économique) និងការរួមចំណែករបស់វាក្នុងការធ្វើឱ្យសង្គមនានារបស់យើងទទួលបានស្តិរភាព និងវិបុលភាព; **យើងលើកទឹកចិត្ត**ឱ្យមានការអនុវត្តគម្រោងធំៗដែលមានភាពច្បាស់លាស់ ឱ្យមានពិពិធកម្មភាពជាដៃគូ ឱ្យមានភាពសុខុដុមនីយកម្មក្របខ័ណ្ឌបទប្បញ្ញត្តិ ឱ្យមានការសម្រួលនីតិវិធីរដ្ឋបាល ក៏ដូចជាឱ្យមានការលើកកម្ពស់តម្លាភាពនិងឧត្តមានុវត្តន៍ ក្នុងគោលដៅជំរុញការវិនិយោគនិងកំណើនសេដ្ឋកិច្ចយូរអង្វែង ;

22). ក្នុងន័យនេះ **យើងសម្រេចថា**នឹងពង្រឹងរចនាសម្ព័ន្ធនៃហ្វ្រង់កូហ្វូនីសេដ្ឋកិច្ច ដោយអំពាវនាវឱ្យរួមគ្នាគិតគូរអំពីតួនាទីរបស់តួអង្គពាក់ព័ន្ធ អំពីភាពស៊ីសង្វាក់គ្នារវាងសកម្មភាពរបស់ពួកគេ និងរបៀបបែបបទដើម្បីអនុវត្តគំនិតផ្តួចផ្តើមទាំងនោះប្រកបដោយប្រសិទ្ធភាពខ្ពស់ និងដើម្បីទទួលបាននូវលទ្ធផលដែលអាចវាស់វែងបាន តាមរយៈការតាមដានត្រួតពិនិត្យជាប្រចាំ ;

23). **យើងលើកទឹកចិត្ត**ដល់គំនិតផ្តួចផ្តើមនានា ដែលលើកកម្ពស់ការទទួលបានការងារសមហេតុផលភាពការអភិវឌ្ឍសមត្ថភាពនិងឱកាសសេដ្ឋកិច្ចសម្រាប់ស្ត្រីនិងយុវជន ជាអាទិ៍នៅក្នុងវិស័យផ្សេងៗដែលនាំឆ្ពោះទៅរកអន្តរកាលឌីជីថល សេដ្ឋកិច្ចបៃតង ឧស្សាហកម្មវប្បធម៌ និងច្នៃប្រឌិត ព្រមទាំងនវានុវត្តន៍ ;

24). **យើងទទួលស្គាល់**ថា ការកៀរគរបណ្តាតួអង្គសេដ្ឋកិច្ច គឺជាកត្តាជំរុញដ៏សំខាន់មួយនៃកិច្ចសហប្រតិបត្តិការរវាងបណ្តារដ្ឋនិងរដ្ឋាភិបាលនៃអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ដែលការណ៍នេះត្រូវតែផ្តល់ប្រយោជន៍ឱ្យគ្នាទៅវិញទៅមក; ក្នុងន័យនេះ យើងលើកទឹកចិត្តដល់រាល់គំនិតផ្តួចផ្តើមពាក់ព័ន្ធទាំងអស់ ដែលគោរពយ៉ាងពេញលេញអធិបតេយ្យភាពនិងក្របខ័ណ្ឌគតិយុត្តិនៃបណ្តាប្រទេសសមាជិកនានា ;

25). **យើងទទួលស្គាល់**ថា ផលប៉ះពាល់ដល់សន្តិភាពនិងសន្តិសុខពីសំណាក់វិបត្តិសកលទាំងបី (បម្រែបម្រួលអាកាសធាតុ , ការបាត់បង់ជីវចម្រុះ និងផ្សែងពុល) គឺជាបញ្ហាប្រឈមធំបំផុតសម្រាប់មនុស្សជាតិ ; ក្នុងន័យនេះ យើងអំពាវនាវឱ្យបណ្តាប្រទេសសមាជិកហ្វ្រង់កូហ្វូនី ពង្រឹងការចូលរួម

ចំណែករបស់ខ្លួន ក្នុងការអនុវត្តកិច្ចសន្យាអន្តរជាតិសំខាន់ៗ ដែលពាក់ព័ន្ធទៅនឹងបរិស្ថាន; ជាពិសេសកិច្ចព្រមព្រៀងទីក្រុងប៉ារីស (ឆ្នាំ ២០១៥) ក្របខ័ណ្ឌសកលស្តីអំពីជីវចម្រុះទីក្រុងគុនមីង-ម៉ុងរ៉េអាល់ (ឆ្នាំ ២០២២) និងកិច្ចព្រមព្រៀងក្រោមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ស្តីពីការអភិរក្សនិងការប្រើប្រាស់ជីវចម្រុះសមុទ្រប្រកបដោយចីរភាព នៅក្នុងតំបន់ដែលស្ថិតនៅក្រៅដែនសមត្ថកិច្ចជាតិ (BBNJ) (ឆ្នាំ ២០២៣); យើងស្វាគមន៍លទ្ធផលបានមកពីសន្និសីទលើកទី ១៧ ស្តីពីអាកាសធាតុ (COP17) អនុសញ្ញាស្តីពីជីវចម្រុះ (CBD) ដែលបានប្រព្រឹត្តទៅនៅទីក្រុងអេរ៉ៅន (ប្រទេសអាកមេនី) ក្នុងខែតុលា ឆ្នាំ២០២៦; យើងអំពាវនាវឱ្យមានការរួមចំណែកប្រកបដោយប្រសិទ្ធផលពីសំណាក់អង្គការហ្វ្រង់កូហ្វូនី ក្នុងកិច្ចការនៃសន្និសីទលើកទី៣១ នៃសន្និសីទបណ្តា ភាគីនៃអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលបានប្រព្រឹត្តទៅនៅទីក្រុងអង់តាល់យ៉ា (ប្រទេសតួកគី) នៅថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ២០២៦ ព្រមទាំងនៅក្នុងសន្និសីទនៃរដ្ឋភាគីលើកទី ១ នៃកិច្ចព្រមព្រៀង BBNJ នៅឆ្នាំ ២០២៧;

26). **យើងបញ្ជាក់ជាថ្មី**ថា ការគោរពនិងការការពារភាពចម្រុះវប្បធម៌និងភាសា មានសារៈសំខាន់សម្រាប់កិច្ចសន្ទនារវាងបណ្តាប្រជាជន ដើម្បីបុព្វហេតុសន្តិភាព; យើងបញ្ជាក់ជាថ្មីនូវការគាំទ្ររបស់យើងចំពោះការតស៊ូមតិហ្វ្រង់កូហ្វូន ដែលជៅទៅរកភាពងាយស្រួលក្នុងការស្វែងរកខ្លឹមសារនានានៅក្នុងថ្នាលឌីជីថលទាំងឡាយ ស្របទៅតាមការប្តេជ្ញាចិត្តដែលមាននៅក្នុងសេចក្តីប្រកាសនៃសន្និសីទបណ្តារដ្ឋមន្ត្រីក្រសួងវប្បធម៌ហ្វ្រង់កូហ្វូនីលើកទី៥ (ទីក្រុងកេបិក នៅខែឧសភា ឆ្នាំ ២០២៥); ក្នុងន័យនេះ **យើងគាំទ្រ**កិច្ចខិតខំប្រឹងប្រែងរបស់អង្គការយូណេស្កូ ក្នុងការកែសម្រួលអនុសញ្ញាឆ្នាំ ២០០៥ ឱ្យកាន់តែសមស្របទៅនឹងបរិបទឌីជីថល ;

27). **យើងបញ្ជាក់សារជាថ្មី**ថា កីឡាក៏ដូចជាវប្បធម៌ដែរ គឺជាកត្តានាំឱ្យមានសុកមង្គលក្នុងការអភិវឌ្ឍខ្លួនឯងផ្ទាល់និងនាំឱ្យមានលំហនៃស្ងប់ការរួបនីយកម្ម ហើយយើងបញ្ជាក់សារជាថ្មីទៀតថា ព្រឹត្តិការណ៍ប្រកួតកីឡាអន្តរជាតិ ពិតជាជួយសម្រួលដល់ការខិតចូលជិតគ្នារវាងបណ្តាប្រជាជននានា ជាពិសេសរវាងបណ្តាយុវជន; **យើងបញ្ជាក់ជាថ្មី**នូវសារៈសំខាន់នៃការពង្រឹងពង្រីកគោលនយោបាយកីឡាសម្រាប់យុវជន; **យើងអបអរសាទរ**ចំពោះការរៀបចំកីឡាអូឡាំពិកយុវជនលើកទី៤ ដែលបានប្រព្រឹត្តទៅនៅទីក្រុងដាកា (សេណេហ្គាល់) និងជាលើកដំបូងបង្អស់នៅក្នុងទ្វីបអាហ្វ្រិក; **យើងក៏លើកទឹកចិត្ត**ផងដែរឱ្យមានការចូលរួមទូលំទូលាយក្នុងការប្រកួតកីឡាហ្វ្រង់កូហ្វូនីលើកទី១០ នៅទីក្រុងអេរ៉ៅន (អាកម៉េនី) នៅឆ្នាំ២០២៧ខាងមុខ ហើយយើងជូនពរឱ្យព្រឹត្តការណ៍កីឡានេះប្រព្រឹត្តទៅដោយជោគជ័យ;

28). **យើងទទួលស្គាល់**ថា បេតិកភណ្ឌវប្បធម៌និងធម្មជាតិ មិនត្រឹមតែតំណាងឱ្យការចងចាំជាសមូហភាពរួមប៉ុណ្ណោះទេ ប៉ុន្តែក៏ជាគន្លឹះយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព, សម្រាប់បរិយាបន្នសង្គម-សេដ្ឋកិច្ច និងសម្រាប់ការផ្ទេរមរតកអស់ទាំងនេះដល់យុវជនគ្រប់ជំនាន់; **យើងសម្រេច**ពង្រឹងជំនាញនិងបទពិសោធន៍របស់ហ្វ្រង់កូហ្វូនី ពាក់ព័ន្ធនឹងការលើកកម្ពស់សមត្ថភាពជួសជុលនិងសមត្ថភាពអភិរក្សបេតិកភណ្ឌនានា ទាំងក្នុងអំឡុងពេលជម្លោះនិងទាំងក្រោយជម្លោះ;

29). **យើងកោតសរសើរ**ជាពិសេស ចំពោះសកម្មភាពនៃបណ្តាញឌីជីថលហ្វ្រង់កូហ្វូនី (RFN) សម្រាប់ជាប្រយោជន៍ដល់បេតិកភ័ណ្ឌឯកសារហ្វ្រង់កូហ្វូនី; ហើយយើងលើកទឹកចិត្តឱ្យបន្តសកម្មភាពទាំងអស់នេះ ដែលក្នុងនោះមានការពង្រឹងសមត្ថភាពសំដៅកាត់បន្ថយវិសមភាពឌីជីថល ;

30). **យើងព្រួកជាថ្មី**ឡើងវិញថា ភាពខ្លាំងរបស់ហ្វ្រង់កូហ្វូនី គឺបិតនៅលើភាពចម្រុះនៃបណ្តាតួអង្គរបស់ខ្លួន, និងសកម្មភាពរួមរបស់តួអង្គទាំងអស់នេះ តម្រង់ទៅកាន់ទិសតែមួយ; **យើងផ្តល់ការគាំទ្រ**ពេញទំហឹងដល់ប្រតិបត្តិករផ្ទាល់ និងដល់ប្រតិបត្តិកទទួលស្គាល់ដោយកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី ព្រមទាំងដល់គ្រប់សន្និសីទរដ្ឋមន្ត្រីអចិន្ត្រៃយ៍ហ្វ្រង់កូហ្វូនី; ហើយ**យើងអំពាវនាវ**ឱ្យពង្រឹងសហថាមវន្តដោយពឹងផ្អែកជាពិសេសលើក្រុមប្រឹក្សាសហប្រតិបត្តិការ (របស់អង្គការហ្វ្រង់កូហ្វូនី)។

31). **យើងកោតសរសើរ**ចំពោះសកម្មភាពរបស់សភាប្រើប្រាស់ភាសាបារាំង (APF) ដើម្បីសន្តិភាព ការបង្ការជម្លោះនិងការលើកកម្ពស់នីតិរដ្ឋ និងកិច្ចសន្ទនាប្រជាធិបតេយ្យនៅកណ្តាលលំហហ្វ្រង់កូហ្វូនី; ហើយ**យើងទទួលដឹងឮ**នូវបំណងប្រាថ្នារបស់ស្ថាប័នខាងលើនេះ ក្នុងការក្លាយជាសមាជិកសង្កេតការណ៍របស់អង្គការសហប្រជាជាតិ ;

32). ជាចុងក្រោយ**យើងទទួលស្គាល់** ការចូលរួមចំណែកដ៏វិសេសវិសាល និងសំខាន់បំផុតរបស់គ្រប់ប្រតិបត្តិករផ្ទាល់និងទទួលស្គាល់ដោយកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី ដែលរួមចំណែកក្នុងបុព្វហេតុ សន្តិភាព ដើម្បីវិបុលភាពរួមនិងស្ថិរភាពយូរអង្វែង ដែលអនុវត្តសកម្មភាពជាប្រចាំថ្ងៃយ៉ាងជិតស្និទ្ធជាមួយប្រជាជនរួមមាន៖ សមាគមអន្តរជាតិអភិបាលក្រុងនិយាយភាសាបារាំង (AIMF) តាមរយៈកម្មវិធីនានាដែលជំរុញកិច្ចសហប្រតិបត្តិការអន្តរព្រំដែននិងកិច្ចសន្ទនាតំបន់; សាកលវិទ្យាល័យ Senghor; បណ្តាញផ្សព្វផ្សាយសាធារណៈពហុភាគី TV5; និងទីភ្នាក់ងារឧត្តមសិក្សាប្រើប្រាស់ភាសាបារាំង(AUF) ; លើសពីនេះ **យើងព្រួក**ជាថ្មីឡើងវិញ នូវភាពចាំបាច់បំផុតនៃការចូលរួមធ្វើការរួមគ្នា ដើម្បីជានានិរន្តរភាព និងការបន្តកៀរគរប្រភពហិរញ្ញវត្ថុសម្រាប់ស្ថាប័នទាំងនេះ ;

*****